ក្រសួងបរិស្ថាន
Ministry of Environment

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
Ministry of Econimy and Finance

# សេចក្តីណែនាំអន្តរក្រសួង
# ស្តីពី
# ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៧

# សាវតា

- រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ១១៣ អនក្រ.បក  ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីផ្ទេរមុខងារនេះឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក
- ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានបានដាក់ចេញសារាចរអន្តរក្រសួងលេខ ១០៧០ សជណ.បស្ថ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអនុក្រឹត្យគ្រប់គ្រងសំរាម សំណល់ទីប្រជុំជន
- ក្រុមការងារអន្តរក្រសួង បាន និងកំពុងរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

# សាវតា

- ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន បាន ដាក់ចេញនូវ**សេចក្តីណែនាំលេខ១៤១១ សជណ.បស្ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងអំឡុងពេលដែលប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃសេវាសំរាម សំណល់រឹងទីប្រជុំជនពុំទាន់បានដាក់ចេញ

# ១. ការកំណត់កម្រៃសេវាប្រមូលសំរាម

- **រដ្ឋបាលរាជធានី ក្រុង និងស្រុកទាំងអស់** ត្រូវកំណត់កម្រៃសេវាគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អនុលោមកម្រៃសេវាសំរាមសំណល់រឹងដែលបាននិងកំពុងអនុវត្តនាពេលបច្ចុប្បន្ននៅតាមតំបន់នីមួយៗ
- **ចំពោះរដ្ឋបាលក្រុង ស្រុកដែលពុំទាន់មានការកំណត់កម្រៃសេវាគ្រប់គ្រងសំរាមសំណល់រឹង ទីប្រជុំជន** ត្រូវធ្វើការសិក្សា ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន

# ១. ការកំណត់កម្រៃសេវាប្រមូលសំរាម

- ការកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន **ត្រូវធ្វើឡើងដោយដីការបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** និងត្រូវចម្លងជូនក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលខេត្ត មន្ទីរបរិស្ថាន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ**នឹងត្រូវពិនិត្យកែសម្រួលឡើងវិញឱ្យបានសមស្រប** នៅពេលដែលប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបានដាក់ចេញ។

# ២. ការអនុវត្តអនុក្រឹត្យ និងសារាចរអន្តរក្រសួង

- ក្រុមការងារអន្តរក្រសួង  រដ្ឋបាលខេត្ត និងមន្ទីរបរិស្ថាន រាជធានី/ខេត្ត ត្រូវសម្របសម្រួល និងផ្តល់ការគាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមស្មារតីនៃអនុក្រឹត្យនិងសារាចរអន្តរក្រសួង
- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំចាត់ចែងអនុវត្តមុខងារគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជនឱ្យបានឆាប់តាមស្មារតីនៃអនុក្រឹត្យនិងសារាចរអន្តរក្រសួងព្រមទាំងត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងបរិស្ថានអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តមុខងារនេះ។

# សូមអរគុណ!